# ផ្សព្វផ្សាយចំណេះដឹងការប្រែប្រួលអាកាសធាតុ និងផែនការយុទ្ធសាស្ត្រឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុសម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ



នាយកដ្ឋានប្រែប្រួលអាកាសធាតុ បានរៀបចំសិក្ខាសាលាថ្នាក់ក្រោមជាតិលើកទី៦ ស្តីពីការលើកកម្ពស់ចំណេះដឹងប្រែប្រួលអាកាសធាតុ ជូនមន្ត្រីថ្នាក់ក្រោមជាតិ នៅថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៤ នៅខេត្តរតនគីរី ដោយមានការគាំទ្រថវិកាពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដោយមានចូលរួមពីស្ថាប័នមន្ទីរពាក់ព័ន្ធ អភិបាល អភិបាលរងស្រុក និងអង្គាធរមូលដ្ឋានខេត្តរតនគិរី និងខេត្តស្ទឹងត្រែង សរុបប្រមាណ ៥០នាក់ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រែប្រួលអាកាសធាតុ របៀបឆ្លើយតបនឹងបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣។

ឯកឧត្តមបណ្ឌិត **ទិន ពន្លក** អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង នៃក្រសួងបរិស្ថាន បានមានប្រសាសន៍នៅក្នុងពិធីបើកថា "ដើម្បីបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងវិស័យពាក់ព័ន្ធនានា ក៏ដូចជាក្នុងការសម្របសម្រួលបណ្តាសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក្នុងចំណោមភាគីពាក់ព័ន្ធឱ្យមានប្រសិទ្ធិភាព ជាការចាំបាច់យើងត្រូវកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងជូនថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈជនទូទៅ ក៏ដូចជាសិស្ស-និស្សិតនៅទូទាំងប្រទេសកម្ពុជា"។

ឯកឧត្តម **ណាប់ ប៊ុនហេង** អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី ក៏បានលើកឡើងពីបញ្ហាប្រឈមអវិជ្ជមានដែលបង្កដោយការប្រែប្រួលអាកាសធាតុ មកលើការរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ឯកឧត្តមបានថ្លែងពីសារៈសំខាន់នៃការលើកកម្ពស់ចំណេះដឹងប្រែប្រួលអាកាសធាតុ ជូនស្ថាប័នទាំងអស់ និងអ្នកពាក់ព័ន្ធ ជាពិសេសប្រជាពលរដ្ឋឱ្យបានយល់ច្បាស់ពីមូលហេតុនៃការប្រែប្រួលអាកាសធាតុ ទាំងផ្នែកបន្សាំ កាត់បន្ថយ និងអភិវឌ្ឍន៍បៃតងជាពិសេសមន្ទីរទាំងអស់ត្រូវយកចិត្តទុកដាក់បញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការរបស់ស្ថាប័នរបស់ខ្លួន។

សិក្ខាសាលារយៈពេលពីរថ្ងៃនេះផ្តោតទៅលើប្រធានបទ ដូចជា ទស្សនៈប្រជាជនទៅលើការប្រែប្រួលអាកាសធាតុ មូលហេតុ និងផលប៉ះពាល់ ការឆ្លើយតបថ្នាក់ជាតិ និងអន្តរជាតិ វិធានការបន្សាំ កាត់បន្ថយ ការគណនាការបញ្ចេញឧស្ម័នកាបូនិច និងការបញ្ជ្រាបផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣។